អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែមីនា

លេខ ៥១/២៦ ចេញផ្សាយផ្សាយ ខែមីនា ឆ្នាំ២០២៦

## ប្រភេទទ្រព្យសកម្ម



ទ្រព្យសកម្មគឺជាធនធានគ្រប់គ្រងដោយស្ថាប័ន ដែល កើតឡើងដោយសារព្រឹត្តិការណ៍កន្លងមករបស់ស្ថាប័ន ដូចជាការទិញ, ការបង្កើត, ការផ្ទេរ, ឬ អំណោយជាដើម។ ទ្រព្យសកម្មដើរតួនាទីក្នុងការគាំទ្រសក្តានុពលក្នុងការរកប្រាក់ចំណូល និងប្រតិបត្តិមុខងារ និងភារកិច្ចរបស់ស្ថាប័ននីមួយៗ។ ទ្រព្យសកម្មចាំបាច់ត្រូវធ្វើការរាយការណ៍ក្នុងតារាងតុល្យការ ដែលជារបាយការណ៍ហិរញ្ញវត្ថុដ៏សំខាន់របស់ស្ថាប័ន។

ទ្រព្យសកម្មត្រូវបានបែងចែកជា៥ ប្រភេទរួមមាន៖

**១.ទ្រព្យសកម្មរយៈពេលខ្លី** គឺជាធនធាន ដែលត្រូវបានរំពឹងថានឹងបម្លែងទៅជាសាច់ប្រាក់ ឬប្រើប្រាស់ក្នុងរយៈពេលតិចជាងមួយឆ្នាំ។

ទ្រព្យសកម្មរយៈពេលខ្លីមានដូចជា សាច់ប្រាក់, ប្រាក់ឈ្នួលបង់មុន, និងសន្និធិ។ល។

**២.ទ្រព្យ រោងចក្រ និងបរិក្ខារ** គឺជាធនធានដែលមានអាយុកាលរំពឹងទុកលើសពីមួយឆ្នាំ។

ទ្រព្យ រោងចក្រ និងបរិក្ខារ មានដូចជា ដី អាគារ, គ្រឿងចក្រ, និងយានយន្តដែលស្ថាប័នប្រើប្រាស់ដើម្បីដំណើរការប្រតិបត្តិការរបស់ខ្លួន។ ទ្រព្យសកម្មទាំងអស់នេះ ត្រូវបានចុះបញ្ជីក្នុងតារាងតុល្យការរបស់ស្ថាប័នជាទ្រព្យសកម្មរយៈពេលវែង ហើយត្រូវធ្វើរំលស់ទៅតាមអាយុកាលនៃការប្រើប្រាស់។

**៣.ទ្រព្យសកម្មអរូបីយ៍** គឺជាទ្រព្យដែលគ្មានរូបរាងប៉ុន្តែវាមានតម្លៃសេដ្ឋកិច្ចនិងផ្តល់ផលប្រយោជន៍រយៈពេលវែងដល់ម្ចាស់ដែលជាអ្នកកាន់កាប់ទ្រព្យនោះ។

ទ្រព្យសកម្មអរូបីយ៍ មានដូចជាពាណិជ្ជនាម, ពាណិជ្ជសញ្ញា , កេរ្តិ៍ឈ្មោះ , អាជ្ញាបណ្ណ, និងសិទ្ធិពិសេស ។ល។

**៤.ទ្រព្យសកម្មហិរញ្ញវត្ថុ** គឺជាទ្រព្យដែលកើតចេញពីការវិនិយោគលើមូលបត្ររបស់ស្ថាប័នដទៃ។

ទ្រព្យសកម្មហិរញ្ញវត្ថុមានដូចជាភាគហ៊ុន,សញ្ញាប័ណ្ណ, និងឧបករណ៍និស្សន្ទ។ល។

**៥.ទ្រព្យសកម្មឌីជីថល** គឺជាវត្ថុមានតម្លៃណាមួយ ដែលមានទម្រង់ជាឌីជីថល ឬរក្សាទុកលើប្រព័ន្ធអេឡិចត្រូនិច ជាពិសេសតាមរយៈបច្ចេកវិទ្យា block chain ឬ Distributed ledger Technology ( DLT )។

ទ្រព្យសកម្មឌីជីថល មានដូចជា Cryptoassets/ Cryptocurrency, Stable coins ,NFTs , Security និង Tokens។



អត្ថបទ ៖ លោក **ថូ គឹមហាក់**

**ឯកសារយោង៖**ឧត្តមានុវត្តន៍នៃការគ្រប់គ្រងទ្រព្យសកម្ម របស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ**អ.ស.ហ.**



ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ. ស. ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។